**ស្ថានទូតអូស្ត្រាលី**
**ភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ២០១៨

## ពិធីជួបជុំសំរាប់បណ្ដាញអប់រំអូស្ត្រាលី

ស្ថានទូតអូស្ត្រាលីរួមជាមួយ IDP Education Cambodia នឹងរួមគ្នារៀបចំពិធីជួបជុំសំរាប់បណ្ដាញអប់រំអូស្ត្រាលី នារាត្រីនេះ។ កម្មវិធីនេះនឹងមានការចូលរួមពី អតីតនិស្សិតកម្ពុជាដែលបានបញ្ចប់ការសិក្សាពីប្រទេសអូស្ត្រាលី អ្នកពាក់ព័ន្ធ និងតំណាងមកពីសកលវិទ្យាល័យនានារបស់អូស្ត្រាលី ដើម្បីផ្សព្វផ្សាយនិងបង្ហាញថា ប្រទេសអូស្ត្រាលីគឺជាគោលដៅសំរាប់ការសិក្សាដែលនាំមុខគេ។

ភារៈធារីស្ថានទូតអូស្ត្រាលី អ្នកស្រី រូតស៍ ស្ទូវ៉ាត (Ruth Stewart) មានប្រសាសន៍ថា « បទពិសោធន៍ពីការសិក្សាថ្នាក់ឧត្តមសិក្សានៅប្រទេសអូស្ត្រាលី ផ្តល់ដល់អនាគតអ្នកដឹកនាំកម្ពុជា នូវជំនាញនិងបទពិសោធន៍ ដែលអាចជួយអោយពួកគេចូលរួមចំណែកកាន់តែប្រសើរសំរាប់ជោគជ័យរបស់កម្ពុជា។»

អ្នកស្រីបានបន្តទៀតថា « ប្រព័ន្ធសិក្សាររបស់អូស្ត្រាលី ជួយនិស្សិតអោយមានទំនុកចិត្តខ្លួនឯងខ្ពស់ កសាងជំនាញពិតប្រាកដ និងជំរុញឱ្យមានការគិតគូរដោយឯករាជ្យ ដែលកត្តាទាំងនេះ អាចរួមចំណែកអោយពួកគេទទួលបានជោគជ័យក្នុងជីវិតនៅពេលក្រោយ»។

កម្មវិធីនេះនឹងចូលរួមអបអរសាទរដល់សមិទ្ធផលរបស់អតីតនិស្សិតកម្ពុជាដែលបានបញ្ចប់ការសិក្សាពីអូស្ត្រាលីផងដែរ។ សមាគមអតីតនិស្សិតកម្ពុជាមកពីអូស្ត្រាលី នឹងប្រគល់ពានរង្វាន់ជូនអតីតនិស្សិតដែលលេចធ្លោប្រចាំឆ្នាំ២០១៨ ចំនួនបីរូប រួមមាន៖ ពានរង្វាន់អតីត

និស្សិតឆ្នើមជាងគេប្រចាំឆ្នាំ ពានរង្វាន់ភាពជាអ្នកដឹកនាំវ័យក្មេង និងពានរង្វាន់ភាពជាអ្នកដឹកនាំសហគមន៍។

ការសិក្សានៅប្រទេសអូស្ត្រាលីគឺបទពិសោធន៍នៃការផ្លាស់ប្តូរឆាកជីវិតសំរាប់និស្សិតកម្ពុជាជាច្រើនរូប។ ចាប់តាំងពីឆ្នាំ១៩៩៤មក រដ្ឋាភិបាលអូស្ត្រាលីបានផ្តល់អាហារូបករណ៍ជិត ៧៥០កន្លែង ដល់ប្រជាជនកម្ពុជាអោយបានទៅសិក្សានៅប្រទេសអូស្ត្រាលី។ ក្នុងឆ្នាំ២០១៧ មានសិស្ស និស្សិតកម្ពុជាច្រើនជាង១៨០០នាក់ បានទៅសិក្សានៅតាម សាលា សកលវិទ្យាល័យ ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ និង មជ្ឈមណ្ឌលភាសាអង់គ្លេសនានា នៅប្រទេសអូស្ត្រាលី។ ចំនួននេះមានការកើនឡើង២៨ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au